ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំយុវជន និង កីឡា
លេខ :៤១១ អយក.ប្រក

# ប្រកាស
## ស្តីពីការបើកសាលាបឋមសិក្សា វត្តជីនថន

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិត របស់គណៈកម្មការសាងសង់សាលាបឋមសិក្សា ខ្លបរុន ដោយមានចំណារឯកភាព ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្ត កំពត ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២
- តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១** :-បើកសាលាបឋមសិក្សា វត្តជីនថន ជាផ្លូវការដែលមានទីតាំងស្ថិតនៅភូមិ ខ្លបរុន ឃុំ ផ្លូវម៉ែង ស្រុក ជុំគិរី ខេត្ត កំពត ជាឧបសម្ព័ន្ធ សាលាបឋមសិក្សា ខ្លបរុន ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :-សាលាបឋមសិក្សា វត្តជីនថន ត្រូវមានប្រធានក្រុមម្នាក់ទទួលខុសត្រូវរួមជាមួយនាយក សាលាបឋមសិក្សា ខ្លបរុន ។

**ប្រការ៣** :-បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** :-នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពត** ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក ជុំគិរី នាយកសាលាបឋមសិក្សា ខ្លបរុន និងប្រធានក្រុម សាលាឧបសម្ព័ន្ធ វត្តជីនថន មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ ២០០២
ជ-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

**អ៊ឹម-សិទ្ធី**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាបជាពត៌មាន"
- សាលាខេត្ត កំពត "ជូនជ្រាបជាពត៌មាន"
- ដូចប្រការ ៤
- កាលប្បវត្តិ
- ឯកសារ នា.បម